**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ ព្រហស្បតិ៍ ១០ រោច ខែ អស្សុជ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០២២*

# សេចក្តីជូនដំណឹង
## ស្តីពី
## សិក្ខាសាលាផ្សព្វផ្សាយស្តីពី
## "វេបផតថលសម្រាប់ធុរកិច្ច និង សេដ្ឋកិច្ចឌីជីថលកម្ពុជា"

នារសៀលថ្ងៃទី **២៧ ខែ តុលា ឆ្នាំ ២០២២ វេលាម៉ោង ២:០០ នាទីរសៀល ដល់ម៉ោង ៥:៤០ នាទីល្ងាច** ខាងមុខនេះ គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" និងក្រុមហ៊ុន Meta នឹងសហការគ្នារៀបចំសិក្ខាសាលាស្តីពី **"វេបផតថលសម្រាប់ធុរកិច្ច និង សេដ្ឋកិច្ចឌីជីថលកម្ពុជា"** ក្រោមអធិបតីភាពរបស់ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ (Hyatt Regency Phnom Penh hotel)។ សិក្ខាសាលានេះនឹងមានការចូលរួមពីតំណាងក្រសួង-ស្ថាប័ន ពាក់ព័ន្ធ, វិស័យឯកជន, សមាគម និង សង្គមស៊ីវិល។

សិក្ខាសាលានេះត្រូវបានរៀបចំឡើង ក្នុងគោលបំណងផ្សព្វផ្សាយឱ្យបានទូលំទូលាយទៅកាន់វិស័យឯកជន និងវិស័យសាធារណៈ នូវវេបផតថល និងគេហទំព័រសំខាន់ៗ សម្រាប់ធុរកិច្ច និង សេដ្ឋកិច្ចឌីជីថល រួមមានគេហទំព័ររបស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល (www.digitaleconomy.gov.kh), ថ្នាលធុរកិច្ច (www.business.gov.kh), ថ្នាលធុរកិច្ចថ្មីកម្ពុជា (www.startupcambodia.gov.kh), ថ្នាលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច Go4eCam របស់ក្រសួងពាណិជ្ជកម្ម និង ថ្នាលសេដ្ឋកិច្ចឌីជីថល (www.dep.kh) ដែលជាកិច្ចសហការរវាងក្រុមហ៊ុន Meta និងអង្គការទិន្នន័យអំពីការអភិវឌ្ឍ (Open Development Cambodia)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងអ្នកសារព័ត៌មានទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងតាមដានការផ្សាយផ្ទាល់ពីគេហទំព័រហ្វេសប៊ុករបស់គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល និងមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" តាមកាលបរិច្ឆេទ និងពេលវេលាខាងលើ កុំបីអាក់ខាន។

(២) **ថ្នាលធុរកិច្ច** (www.business.gov.kh) ប្រមូលផ្តុំព័ត៌មានស្តីពីការធ្វើធុរកិច្ចនៅកម្ពុជា ដាក់ក្នុងកន្លែងតែមួយ សម្រួលដល់ធុរជនក្នុងការស្វែងរកព័ត៌មានស្តីពីការស្នើសុំវិញ្ញាបនបត្រ, អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតធ្វើអាជីវកម្ម និងកិច្ចការងារផ្សេងៗទៀតក្នុងការធ្វើធុរកិច្ចនៅកម្ពុជា។

(៣) **ថ្នាលធុរកិច្ចថ្មីកម្ពុជា** (www.startupcambodia.gov.kh) ជាផ្នែកមួយនៃកម្មវិធីថ្នាក់ជាតិធុរកិច្ចថ្មីកម្ពុជា បង្កើតឡើងដើម្បីរៀបបញ្ជីនៃតួអង្គក្នុងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីកម្ពុជាសំដៅបង្កើនអន្តរសកម្មរវាងតួអង្គគាំទ្រធុរកិច្ចថ្មី និងប្រព័ន្ធអេកូឡូស៊ីឲ្យកាន់តែមានភាពប្រទាក់ក្រឡា និងរស់រវើក។

(៤) **គម្រោង Go4eCam** ផ្តល់នូវវគ្គខណ្ឌចាំបាច់ដល់សហគ្រាសធុនមីក្រូ តូច និងមធ្យម ក្នុងការធ្វើបរិវត្តកម្មឌីជីថល និងទទួលបានសិទ្ធិប្រើប្រាស់ថវិកាតាមតម្រូវការ ក្នុងការចាប់យកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការធ្វើអាជីវកម្មឱ្យមានលក្ខណៈផ្លូវការ ដើម្បីគាំទ្រដល់ការត្រៀមខ្លួនក្នុងការនាំចេញ។

ទន្ទឹមនេះ, សិក្ខាសាលាក៏បានផ្សព្វផ្សាយពី**វេបផតថលសេដ្ឋកិច្ចឌីជីថល** (www.dep.kh) ដែលជាវេបផតថលផ្តល់ព័ត៌មានស្តីពីសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ដែលរៀបចំឡើងដោយអង្គការទិន្នន័យអំពីការអភិវឌ្ឍ ក្រោមកិច្ចសហការជាមួយក្រុមហ៊ុន Meta ផងដែរ។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងស្របតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ដែលបានមើលឃើញពីសារៈសំខាន់, សក្តានុពល និងកាលានុវត្តភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងជំរុញធុរកិច្ចឌីជីថលនៅប្រទេសកម្ពុជា ដែលក្នុងនោះការទទួលបានទិន្នន័យ និងព័ត៌មានគ្រប់ជ្រុងជ្រោយ និងអាចទុកចិត្តបាន ពីសកម្មភាពសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល តាមរយៈវេបផតថល និងមធ្យោបាយផ្សព្វផ្សាយខាងលើ មានសារៈសំខាន់ក្នុងការជំរុញការចាប់យកឌីជីថល និងបរិយាប័ន្នឌីជីថល និងលើកស្ទួយការយល់ដឹងពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងដំណើរនៃការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ដែលរស់រវើក និងប្រកបដោយបរិយាប័ន្ន។ ទន្ទឹមនេះ, ការរៀបចំសិក្ខាសាលានេះឡើងបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីសារៈសំខាន់នៃសហថាមពល (Synergy) ដែលកើតឡើងរវាងកិច្ចសហប្រតិបត្តិការ និងវិស័យរដ្ឋ និងឯកជន ក្នុងការជំរុញឱ្យមានការចាប់យកឌីជីថល និងការធ្វើបរិវត្តកម្មឌីជីថលនៅលើគ្រប់វិស័យ និងតួអង្គ។

សិក្ខាសាលានេះបានប្រព្រឹត្តទៅយ៉ាងរលូន និងទទួលបានលទ្ធផលគាប់ប្រសើរដូចការរំពឹងទុកថែមទាំងទទួលបានធាតុចូលល្អៗជាច្រើន តាមរយៈការពិភាក្សា, ការចែករំលែកទស្សនាទាន, គំនិតនវានុវត្តន៍ និងបទពិសោធន៍ជាក់ស្តែងពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់។